**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៣២ **អយក.**សណន

# សេចក្តីណែនាំ

## ស្តីពី

## ការលើកកម្ពស់ការិយាល័យមន្ត្រីអប់រំមានបរិស្ថានល្អ និងអនាម័យស្អាត

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតលេខ៦១៦ អយក.ធគអ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំបរិស្ថាន និងអនាម័យនៅតាមអង្គភាព ហើយបានសង្កេតឃើញថា មានអង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិវិស័យអប់រំមួយចំនួនអនុវត្តតាមស្មារតីលិខិតបានល្អប្រសើរ។ ទន្ទឹមនេះ ក៏នៅតែមានអង្គភាពមួយចំនួនទៀតអនុវត្តមិនទាន់បានល្អប្រសើរនៅឡើយ។

ដើម្បីកិត្តិយសក្នុងនាមជាមន្ត្រីគ្រប់គ្រងការងារអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សរបស់ជាតិឱ្យឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ក្រសួងបានកំណត់ចេញជាទស្សនទានស្តីពីការិយាល័យមន្ត្រីអប់រំមានបរិស្ថានល្អ អនាម័យស្អាត ដែលមានគោលការណ៍៣ ជាមូលដ្ឋានគឺៈ វិន័យ(Discipline) បៃតង(Green)និងស្អាត(Clean)ក្នុងគោលដៅលើកកម្ពស់ការយកចិត្តទុកដាក់របស់មន្ត្រីគ្រប់គ្រង និងមន្ត្រីជំនាញតាមគ្រប់អង្គភាពប្រតិបត្តិទាំងថ្នាក់ជាតិ និងក្រោមជាតិ។

យោងតាមស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គ្រប់អង្គភាពថ្នាក់ជាតិ និងគ្រប់អង្គភាពថ្នាក់ក្រោមជាតិវិស័យអប់រំទាំងអស់ ដូចខាងក្រោមៈ

១-ត្រូវបង្កើតឱ្យមានក្រុមការងារមួយសម្រាប់ផ្សព្វផ្សាយខ្លឹមសារទស្សនាទាន ស្តីពីការិយាល័យមន្ត្រីអប់រំមានបរិស្ថានល្អ អនាម័យស្អាត តាមគោលការណ៍ទាំង៣ នៃទស្សនាទានដូចបានជូនភ្ជាប់ ដើម្បីការពង្រឹងការយកចិត្តទុកដាក់របស់មន្ត្រីអប់រំគ្រប់រូបឱ្យមានប្រសិទ្ធភាពខ្ពស់។

២-ត្រូវចាត់តាំងអនុវត្តយុទ្ធនាការការិយាល័យមានបរិស្ថានល្អ អនាម័យស្អាត តាមគោលការណ៍ដែលបានកំណត់ក្នុងឯកសារទស្សទានខាងលើឱ្យបានផុលផុស និងបង្កើតចលនាប្រឡងប្រណាំង ព្រមទាំងផ្សារភ្ជាប់ទៅនឹងការលើកទឹកចិត្តគ្រប់រូបភាព។

៣-ត្រូវមានយន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តរបស់អង្គភាពប្រតិបត្តិក្រោមឱវាទ និងត្រូវរៀបចំរបាយការណ៍ជាទៀងរាល់១ត្រីមាស ស្តីពីលទ្ធផលអនុវត្តនិងការវាយតម្លៃ មកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីមានវិធានការដោះស្រាយបន្ត។

៤-រាល់ការចំណាយផ្សេងៗក្នុងការអនុវត្តយុទ្ធនាការនេះត្រូវប្រើប្រាស់ថវិការបស់អង្គភាពសាមី។

ក្រសួងសង្ឃឹម និងជឿជាក់លើស្មារតីទទួលខុសត្រូវខ្ពស់របស់ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ក្នុងការយកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរសម្រាប់ការលើកកម្ពស់តម្លៃរបស់មន្ត្រីអប់រំ ក៏ដូចជាការធានាបានបរិស្ថានល្អ និងអនាម័យស្អាតដើម្បីផាសុកភាព និងសុខដុមនីយកម្មនៅក្នុងវិស័យអប់រំ យុវជន និងកីឡា។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន**

-សាលារាជធានី ខេត្ត «ដើម្បីជ្រាប»

-អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

-មន្ទីរអប់រំ យុវជន និងកីឡា«ដើម្បីអនុវត្ត»

-ឯកសារ-កាលប្បវត្តិ:អគ.ធគ